# ការសំភាសន៍របស់លោកតា ហ៊ម ពឿង

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ហ៊ម ពឿង

## ការសង្ខេបប្រវត្តិរបស់ លោកតា ហ៊ម ពឿង

លោកតា ហ៊ម ពឿង មានអាយុ80ឆ្នាំ នៅក្នុងឆ្នាំ 2018 លោកតា ហ៊ម ពឿង មានភេទប្រុស លោកតា ហ៊ម ពឿង មានទីលំនៅបច្ចុប្បន្ននៅ ភូមិដក់ពរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

កៈ ចឹងជាដំបូងខ្ញុំអរគុណតាដែរបានអោយខ្ញុំពិភាក្សាដែរទាក់ទងពីប្រវត្តិរបស់តា ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍តា ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់តាយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេតា?

ខៈ បាទ!!

កៈ បាទតាបាទចឹងសំរាប់ខ្ញុំជាអ្នកពិភាក្សាជាមួយតាខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍តាគឺនៅថ្ងៃទី10ខែ4 ឆ្នាំ2018 ភូមិដក់ពរហើតា?

ខៈ បាទៗៗ!!នឹងហើយ។

កៈ ឃុំនឹងឃុំវល្លិ៍សរ ហើតា?

ខៈ ឃុំវល្លិ៍សរ។

កៈ នឹងស្រុកសំរោងទង?

ខ៖ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

ក៖ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ចុះសំរាប់តាមានឈ្មោះពេញរបស់តានឹងមានឈ្មោះអីគេដែរទៅតា?

ខ៖ ខ្ញុំមានឈ្មោះពឿង។

ក៖ មានឈ្មោះអីគេដែរពឿងហោសតា?

ខ៖ មានឈ្មោះហ៊ម ពឿង។

ក៖ ចឹងមានឈ្មោះអម ពឿង?

ខ៖ ទេឈ្មោះហ៊ម ពឿង។

ក៖ អូ៎!!ឈ្មោះហ៊ម ពឿង ចុះមានឈ្មោះហៅក្រៅដែរទេតា?

ខ៖ អត់មានទេ។

ក៖ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះតាអីផ្សេងទេតា?

ខ៖ អត់មានឈ្មោះអីផ្សេងទេនឹង។

ក៖ អូ៎!!បាទតា ចុះសព្វថ្ងៃនឹងតាអាយុប៉ុន្មានដែរទៅតា?

ខ៖ ខ្ញុំនឹងសព្វថ្ងៃខ្ញុំអាយុ80ឆ្នាំនឹង។

ក៖ អូ៎!!ដូចជាតាអាយុច្រើនហាសណាតា?

ខ៖ បាទ!!នឹងហើយ។

ក៖ ចុះដូចជាតានៅម្នាក់ឯងរឺមួយតានៅជាមួយយាយដែរតា?

ខ៖ ខ្ញុំអត់មានយាយទេនឹង។

ក៖ អូ៎!!យាយបានស្លាប់យូរហើយណាតា?

ខ៖ បាទៗ!!នឹងហើយ។

ក៖ ចុះយាយស្លាប់អស់ប៉ុន្មានឆ្នាំដែរហើយតា?

ខ៖ ប្រហែលជាខ្វង់5ឆ្នាំហើយនឹង។

ក៖ អូ!!បាទតា ចុះតាមានចងចាំថាតាបានកើតនៅថ្ងៃខែឆ្នាំណាដែរទេតា?

ខ៖ អត់អត់មានចងចាំទេ។

ក៖ តាអាយុ80ឆ្នាំហោតា?

ខ៖ បាទៗៗ!!នឹង។

ក៖ អូ!!បាទ ចឹងតាកើតនៅឆ្នាំ1938តា ចុះថ្ងៃខែក៏តាអត់ចងចាំដែរណតា?

ខ៖ អត់មានទេ។

ក៖ ចុះតាកើតសំរាប់ឆ្នាំច័ន្ទគតិនឹងតាកើតនៅឆ្នាំអីដែរដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះហាសតា?

ខ៖ ខ្ញុំកើតនៅឆ្នាំថោះ។

ក៖ អូ!!នៅឆ្នាំថោះណតា ចុះតាកើតនៅណាដែរតាមានដឹងទេ?

ខ៖ ខ្ញុំកើតនៅខាងវត្តទទឹប នៅខាងភូមិភ្នាយ។

ក៖ នៅភូមិភ្នាយហោសតា?

ខ៖ នឹងហើយខ្ញុំកើតនៅណុង នេះស្រុកកំណើតខាងយាយនឹង។

ក៖ ចុះគេហៅឃុំអីគេដែរទៅតា?

ខ៖ នៅនោះគេហៅឃុំតាប៉ែន។

ក៖ ឃុំតាប៉ែន ចុះស្រុកអីគេដែរទៅតា?

ខ៖ ឃុំភ្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

ក៖ ចុះតាមានបងប្អូនចំនួនប៉ុន្មាននាក់ដែរតា?

ខ៖ បងប្អូនរបស់ខ្ញុំទាំងអស់ស្លាប់ដែរហោស?

ក៖ បាទតាបាទ?

ខ៖ មានបងប្អូនចំនួន9នាក់នឹង។

ក៖ ចុះតាជាកូនទីប៉ុន្មានដែរតា?

ខ៖ ខ្ញុំជាកូនទី7នឹង។

ក៖ ចុះមានស្រីប៉ុន្មាននាក់ ហើយនឹងប្រុសប៉ុន្មាននាក់ដែរទៅតា?

ខ៖ មានប្រុស3នាក់ នឹងស្រី5នាក់នឹង។

ក៖ ចុះឥឡូវនឹងនៅសល់ប៉ុន្មានដែរនៅរស់ហាសតា?

ខ៖ ឥឡូវនឹងនៅសល់តែ2នាក់នឹង។

ក៖ ចុះតាអាចប្រាប់ឈ្មោះពួកគាត់ដែរទាំងអស់ស្លាប់ដែរចឹងហាសតាមានចងចាំទេ?

ខ៖ ឪពុកនឹងឪពុកគាត់។

ក៖ អត់ទេចង់និយាយបងប្អូនរបស់តាដែរបានស្លាប់ហាស ទាំងអស់នៅរស់ហាសតា?

ខ៖ អូ៎!!ភ្លេចអស់ហើយនឹងកូនអើយ។

ក៖ ប៉ុន្តែអ្នកនៅរស់នឹងមាន2នាក់។

ខ៖ នឹងហើយនឹង។

ក៖ ប៉ុន្តែមានឈ្មោះអីគេខ្លះដែរទៅតា?

ខ៖ អ្នកនៅរស់នឹងមានឈ្មោះនាង ផាន។

ក៖ ហើយនឹងតា?

ខ៖ នឹងហើយ។

ក៖ ប៉ុន្តែគាត់ប្អូនរបស់តា រឺមួយក៏បងរបស់តាដែរតា?

ខ៖ ប្អូនរបស់ខ្ញុំនឹង៣គេមីងនឹង។

ក៖ អូ៎!!បាទតា ចុះតាធ្លាប់មានអនុស្សាវរីយ៍អីជាមួយបងប្អូនរបស់តាដែរ តាធ្លាប់បានលេងអីកាលនៅពីក្មេងដែរទេ ដូចតាលេងឡឹកបាយឡ លេងបិទពួនអីចឹង?

ខ៖  អូ៎!!លេងនឹងលេងមិនអស់ទេចៅអើយកាលពីក្មេងនឹងហាស។

ក៖  លក្ខណៈថាលេងបាញ់ឃ្លី លេងគប់ឈូស?

ខ៖  ខ្ញុំកាលនៅពីតូចខ្ញុំអត់មានដឹងអីទេណាស់ រហូតទាល់តែខ្ញុំធំពេញវ័យណាស់។

ក៖  បាទតានឹងហើយ?

ខ៖  ខ្ញុំឪពុកម្ដាយនឹងអោយទៅនៅវត្ត។

ក៖  អូ៎!!ទៅនៅវត្តហោស?

ខ៖  បាទនឹងហើយ។

ក៖  ចុះតាទៅនៅវត្តនឹងទៅធ្វើអីគេដែរទៅតា?

ខ៖
ទៅនៅវត្តនឹងទៅរៀននៅសាលាយើងនឹងហាសទៅរៀនបួសរៀនអីនឹងខ្សោយអីនឹងហាស
។

ក៖  អូ៎!!បាទតា មានន័យថាអត់បានមានលេងអីជាមួយបងប្អូនរបស់តាទៅ
តាបានភ្លេចហើយណតា?

ខ៖  បាទនឹងបាទភ្លេចហើយ ខ្ញុំធំដឹងក្ដីមើលអត់ដឹងលិចកើតនឹង
ឪពុកម្ដាយរបស់ខ្ញុំយកទៅនៅវត្តថ្មី នៅស្ពឺហោស។

ក៖  អូ៎!!ទៅទាំងអស់គ្នារឺមួយក៏ទៅតែតាម្នាក់ឯងដែរ?

ខ៖  ទៅតែខ្ញុំតែម្នាក់ឯងទេ។

ក៖  គាត់គិតយ៉ាងម៉េចបានគាត់យកតែតាទៅតែម្នាក់ឯងចឹង?

ខ៖  យកទៅនៅវត្តយកទៅផ្ញើរលោក។

ក៖  បាទប៉ុន្តែបងប្អូនរបស់តានឹងនៅផ្ទះ?

ខ៖  បាទគាត់យកខ្ញុំទៅផ្ញើរលោកនឹង អោយលោកយកទៅអោយរៀននៅសាលារៀនអីចឹង ដូចសព្វដង ដូចតែរាល់ដងចឹងហាសអូន។

ក៖  ប៉ុន្តែតាអត់មានបានបួសណាហីតា?

ខ៖  ខ្ញុំបួសបាន3វស្សា។

ក៖  អូ៎ៗ!!ល្អតា ចុះសំរាប់ប្អូនរបស់តា សព្វថ្ងៃនឹងគាត់នៅណាដែរតា?

ខ៖  វានៅត្រពាំងក្រឡឹងហោស។

ក៖  គាត់នៅត្រពាំងក្រឡឹងហោស ចុះគាត់ធ្វើអីគេដែរនៅណុងហាសតា?

ខ៖  វាលក់បាយ។

ក៖  អូ៎!!លក់បាយណតា?

ខ៖  បាទនឹងហើយនៅណុង។

ក៖  ចុះសំរាប់ឪពុករបស់តានឹងមានឈ្មោះអីគេដែរតា?

ខ៖  គាត់មានឈ្មោះហ៊ម។

ក៖  ចុះមានឈ្មោះអីគេដែរហ៊ម ហាសតា?

ខ៖  គាត់មានឈ្មោះ គឹម ហ៊មនឹង។

ក៖  គាត់មានឈ្មោះគឹម ហ៊ម ចុះបើសិនជាមកដល់ឥឡូវនឹងមានដឹងថាប្រហែលជាអាយុប៉ុន្មានដែរទៅ?

ខ៖  អូ៎!!កាលពីគាត់ស្លាប់នឹងគាត់អាយុ60ឆ្នាំនឹង។

ក៖  អូ៎!!គាត់ស្លាប់អស់ប៉ុន្មានដែរតា?

ខ៖  គាត់អាយុ60ឆ្នាំនឹងហើយយើងនៅអាយុ13ឆ្នាំនឹងហាស។

ក៖  ស្លាប់ចឹងគាត់មានអាច្រើនហើយគាត់នឹង?

ខ៖  បាទខ្ញុំកំព្រាតាំងពីខ្ញុំអាយុ13ឆ្នាំនឹងមកហោស។

កៈ បាទតា ចុះឪពុករបស់តានឹងគាត់កើតនៅណាដែរតាមានដឹងទេ?

ខៈ ស្រុកកំណើតរបស់គាត់នឹងនៅណៃត្រពាំងពាក់។

កៈ ស្រុកត្រពាំងពាក់?

ខៈ ត្រពាំងពាក់យើងនៅបែកចាននឹងហាស។

កៈ បាទតា ចុះសំរាប់ម្ដាយរបស់តានឹងមានឈ្មោះអីគេដែរទៅតា?

ខៈ គាត់មានឈ្មោះយាយចិន។

កៈ ចុះគាត់មានឈ្មោះយាយចិន ប៉ុន្តែមានឈ្មោះអីគេចិនដែរតា?

ខៈ គាត់មានឈ្មោះគឹម ចិននឹង។

កៈ ចឹងគាត់ឈ្មោះគឹម ចិនដែរហោស ចុះគាត់កើតនៅណាដែរតាមានចងចាំទេ?

ខៈ គាត់បានកើតនៅត្រពាំងត្រាច។

កៈ កើតនៅត្រពាំងត្រាច?

ខៈ នៅខាងជើងថ្នល់ទទឹងនឹង។

កៈ បាទតា ចុះតា?

ខៈ នៅខេត្តកណ្ដាលនឹង។

កៈ បាទតា។

កៈ ចុះសំរាប់ឪពុករបស់តាពីមុននឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរតា?

ខៈ គាត់ឡើងត្នោតនឹងហាស។

កៈ គាត់ឡើងត្នោត នឹងកូរស្ករត្នោតអីហើយណាតា?

ខៈ បាទៗៗ!!នឹងហើយ។

កៈ ចុះតាចេះកូរស្ករត្នោតដែរទេ?

ខៈ ខ្ញុំថីមិនចេះ។

កៈ ចឹងអត់ចេះទេណតា?

ខៈ ខ្ញុំចេះតើនឹង។

កៈ អូ៎!!តាចេះដែរហោសតា?

ខៈ ខ្ញុំកាលពីខ្ញុំមានប្រពន្ធនឹងខ្ញុំឡើងដើម្បីត្នោតដែរតើ!!

កៈ តាឡើងត្នោតហើយតាធ្វើអីគេទៀតទៅ?

ខៈ ដល់សម័យពលពតនឹង សម័យលុនណុលនឹងខ្ញុំមានបានឡើងត្នោតណា ដល់សម័យពលពតនឹងគេអោយខ្ញុំទៅឡើងត្នោតនឹងរួមនៅខាងកំពង់ស្ពឺហោស។

កៈ អូ៎!!នៅជាមួយចាស់ៗៗផ្សេងៗៗហោសតា?

ខៈ បាទ!!នឹងហើយ។

កៈ បាទតា ចុះសំរាប់ឪពុករបស់តាគាត់ជាមនុស្សកាច រឺមួយក៏ស្លូតដែរតា?

ខៈ អូ៎!!ឪពុករបស់ខ្ញុំនឹងគាត់ស្លូតណាស់។

កៈ ក្មេងដេក៏គាត់មិនដែរខឹងដែរនឹង។

កៈ អូ៎!!ចុះម្ដាយរបស់តាគាត់ស្លូតរឺមួយក៏កាចដែរតា?

ខៈ ម្ដាយរបស់ខ្ញុំនឹងគាត់កាចតិចនឹងហាស។

កៈ ប៉ុន្តែគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរតា?

ខៈ ម្ដាយរបស់ខ្ញុំនឹងគាត់ធ្វើស្រែដែរនឹង។

កៈ អូ៎!!គាត់ធ្វើស្រែដែរហោសតា?

ខៈ គាត់ឡើងដុតភ្លើងត្នោតនឹងធ្វើស្រែ។

កៈ បាទតា ចុះតាមានធ្លាប់ចងចាំអនុស្សាវរីយ៍អីកាលពីនៅជាមួយឪពុកម្ដាយរបស់តាទេ ថាធ្លាប់បានធ្វើអីជាមួយក្នុទៅស្រែអីចឹងហាស?

ខៈ បាទខ្ញុំនៅជាមួយម្ដាយរបស់ខ្ញុំនឹង កាលពីខ្ញុំមកសឹកបួសមកនឹងខ្ញុំនៅជាមួយម្ដាយធ្វើស្រែ ដល់មានប្រពន្ធនឹងខ្ញុំឡើងត្នោត។

កៈ អូ៎!!ឡើងត្នោតរហូតនឹងហោសតា?

ខៈ បាទនឹងហើយ។

កៈ ប៉ុន្តែតាធ្វើស្រែដែរហើមិនមែនតែឡើងត្នោតទេហីតា?

ខៈ បាទធ្វើ បាទនឹងហើយធ្វើកាលនៅជាមួយម្ដាយនឹងធ្វើដែរនឹង។

កៈ បាទតាបាទ
ចុះឪពុកម្ដាយរបស់តានឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់ពួកគាត់ទៅតាដែរទេ?

ខៈ អូ៎!!ខ្ញុំមិនទាន់ទេចៅ ខ្ញុំអត់ដឹងអត់ចងចាំទេចៅ។

កៈ អូ៎!!ភ្លេចអស់ហើយណាតា?

ខៈ បាទៗ!!នឹងហើយ។

កៈ ចុះយាយតាខាងឪពុកនឹងតាមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ អត់អត់មានស្គាល់ទេ។

កៈ ចុះគាត់កើតនៅណាដែរក៏តាមិនដឹងដែរណាតា?

ខៈ បាទ!!នឹងហើយ។

កៈ ចុះយាយតាខាងម្ដាយវិញតា?

ខៈ យាយតាខាងម្ដាយនឹងក៏ខ្ញុំអត់ស្គាល់ដែរនឹង។

កៈ អូ៎!!ចុះតារស់នៅនឹងយូរនៅតា?

ខៈ ខ្ញុំមកនៅនេះគិតទៅវាចូល50ឆ្នាំហើយនឹងនៅក្នុងភូមិនេះ។

កៈ អូ៎!!អស់50ឆ្នាំអូច្រើនឆ្នាំ?

ខៈ បាទនៅនឹង។

កៈ ចុះតាមានបងប្អូនកូនចៅណាដែរគាត់មានទៅរស់នៅក្រៅប្រទេសដែរទេតា?

ខៈ អត់មានទេ។

កៈ អត់ទេហោសតា នៅថៃ វៀតណាម ទៅធ្វើការងារនឹងក៏អត់មានដែរ?

ខៈ បាទអត់មានទេនឹង។

កៈ អូ៎!!បាទ ចុះភរិយារបស់តានឹងមានឈ្មោះអីគេដែរតា?

ខៈ គាត់មានឈ្មោះគាំ។

កៈ ចុះគាត់មានឈ្មោះស្អីគេគាំដែរតា?

ខៈ គាត់មានឈ្មោះហឹម គាំ។

កៈ អូ៎!!មានឈ្មោះហឹមគាំហោសតា?

ខៈ បាទនឹងហើយ។

កៈ ចុះតាមានចងចាំថាតាបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទេ?

ខៈ ខ្ញុំអត់ចងចាំទេដែរនឹង។

កៈ ចុះកូនបងរបស់តានឹងអាយុប៉ុន្មានដែរតាឥឡូវនឹងហាស?

ខៈ កូនរបស់ខ្ញុំនឹងកូនបងគេអត់ដឹងអាយុកូនបងគេបង្អស់នឹងស្លាប់បាត់ហើយនឹង កូនបន្ទាប់ៗនឹងអាយុ50ឆ្នាំហើយនឹង នេះបន្ទាប់អាបងហាសអាយុ50ឆ្នាំ។

កៈ ចឹងមានន័យថាតាការអស់50ឆ្នាំហើយណាតា?

ខៈ នឹងហើយចឹង។

កៈ អូ៎!!បាទតា ចុះសំរាប់នៅពេលដែរតាបានរៀបអាពាហ៍ពិពាហ៍ជាមួយយាយនឹង តើតាជាអ្នកចង់រៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្ដាយជាអ្នករៀបចំអោយដែរ?

ខៈ ឪពុកម្ដាយជាអ្នករៀបអោយនឹងហាស។

កៈ អូ៎!!ពេលណុងមានជាថ្លៃបណ្ណាការទេតា មានជាជំនូនជូនយាយទេតា?

ខៈ មានយើងធម្មតាដូចយើងប្រពៃណីខ្មែរចឹង។

កៈ អូ៎!!ប៉ុន្តែកាលពីជំនាន់ណុងគេជូនច្រើនដែរទេតា?

ខ៖ មានជំនួនច្រើនដែរតានឹងជូនតាស្ដីដណ្ដឹងធម្មតានឹង យើងតាប្រពៃណីនឹង។

ក៖ អូ៎!!បាទ ចុះកាលពីជំនាន់ណុលលុយថ្លៃមែនទេតា?

ខ៖ បាទគោមួយនឹមនឹង3000មួយនឹមនឹងហាស។

ក៖ ចឹងមួយនឹមនឹង3000ណាតា?

ខ៖
បាទមួយនឹម3000នឹងទិញតាំងពីខែវស្សាមកនឹងទាល់ដល់ខែប្រាំងនឹងបានអោយលុយគេនឹង។

ក៖ អូ៎!!ជំពាក់គេឡើងចង់កន្លះឆ្នាំហើយនឹង?

ខ៖ ជំពាក់មួយឆ្នាំនឹងហាស។

ក៖ អូ៎!!អស់មួយឆ្នាំចឹងហោសតា?

ខ៖ យកមកដឹកអូស ធ្វើស្រែធ្វើអីធម្មតាចឹងទៅណាស់
ខែប្រាំងឡើងបានយើងឡើងត្នោតចឹងទៅបាន អោយលុយគេចឹងទៅ។

ក៖ អូ៎!!ចឹងហោសតា?

ខ៖ គោមួយនឹមនឹង3000ទេ។

ក៖ អូ៎!!បាទតា ចុះគេអោយជំពាក់ចឹងគេអត់ខាតទេហោសតា?

ខ៖ អត់អីទេធម្មតានឹងទូរទៅនឹងហាស។

ក៖ គេធ្វើចឹងដែរហោសតា?

ខ៖ បាទនឹងហើយចឹង។

ក៖ ដល់ពេលដែរយើងលក់អោយគេនឹងក៏យើងធ្វើចឹងដែរ?

ខ៖ បាទដូចតែគ្នាចឹង។

ក៖ ចុះយើងមានលុយមកពីណាចាយដែរតា
ដូចថាយើងលក់ហើយយើងចង់យកលុយចាយភ្លាមៗនឹងយើងធ្វើយ៉ាងម៉េចទៅតា?

ខ៖  អត់ទេនឹង

ក៖  ចឹងអត់បានទេហោសតា?

ខ៖  បាទអត់បានទេ ចុះយើងទិញពីខែវស្សា
រហូតដល់ខែប្រាំងចឹងវិញបានយើងអោយគេ។

ក៖  អូ៎!!ចឹងហោស?

ខ៖  សងគេប្រាំរយ រឺមួយពាន់សងគេបន្តាក់ចឹងហាស
បណ្តើរៗដូចយើងបង់លុយការរដ្ឋចឹង។

ក៖  បាទតាបាទនឹង?

ខ៖  មានច្រើនអោយច្រើននឹងមានតិចអោយតិចចឹងទៅណាស់។

ក៖  អូ៎!!ឆាប់ចប់ឆាប់អីណតា?

ខ៖  បាទនឹង។

ក៖  អូ៎!!ល្អតា ចុះតាគិតថានៅពេលដែរតាស្គាល់យាយនឹងតើតាស្គាល់នៅពេលណាដែរតា
ហើយនឹងអស់រយះពេលប៉ុន្មានឆ្នាំដែរតាបានរៀបចំអាពាហ៍ពិពាហ៍ជាមួយយាយចឹងហាស
?

ខ៖  ខ្ញុំស្គាល់គាត់ចឹងខ្ញុំមានបងមានប្រពន្ធនៅស្រុកនេះនឹង។

ក៖  បាទតាបាទនឹង?

ខ៖  ដល់ពេលចឹងខ្ញុំទៅមកទៅមកចឹងទៅ ហើយខ្ញុំដើរលេងទៅមកៗនឹង
ដល់ពេលដែរខ្ញុំបានឃើញ យាយចឹងខ្ញុំប្រាប់ម៉ែខ្ញុំចង់បានកូនគេមួយនឹង។

ក៖  អូ៎!!ចឹងហោសតា?

ខ៖  ថាចង់បានកូនគេមួយនឹង អញ់អត់មានលុយទេនឹង
ហើយខ្ញុំថាស្រេចតែខ្ញុំអោយតែម៉ែឯងចូលទៅ ស្រេចតែខ្ញុំរឿងលុយកាក់នឹង។

ក៖  ដល់ពេលចឹងយើងក៏ចូលទៅ?

ខ៖ ហើយម្ដាយរបស់ខ្ញុំនឹងក៏ចូលទៅ
ហើយរឿងលុយកាក់នឹងម៉ែរបស់ខ្ញុំខ្ញុំប្រាប់ថារឿងលុយកាក់នឹង ម៉ែឯងកុំភ័យ ការខែផល្គុន
នៅខែពិសាកខ្ញុំរកបាន3000។

ក៖ ប៉ុន្តែអានឹងគេបង្គាប់យកប៉ុន្មានដែរទៅ?

ខ៖ ធ្វើផ្ទះអោយនឹងហាស។

ក៖ អូ!!បង្គាប់អោយធ្វើផ្ទះហោសតា?

ខ៖ ថាដូចថៅឯងការចឹងហាសថៅឯងសងផ្ទះអោយគេ។

ក៖ អូ!!ចឹងហោសតា?

ខ៖ ដល់សងផ្ទះហើយនឹងផ្ទះនឹងសំរាប់កូនឯងការហើយសំរាប់កូនថៅឯងប្ដីប្រពន្ធនឹង។

ក៖ អូ!!ចុះបើអត់ចេះធ្វើសងផ្ទះនឹងធ្វើម៉េចទៅ?

ខ៖ អត់សងផ្ទះនឹងយើង។

ក៖ យើងជួលគេទៅ?

ខ៖ បាទផ្ទះនឹងទៅដល់ពេលដែរយើងការហើយនឹងយើងមានផ្ទះណានៅ
ហើយយើងត្រូវតែធ្វើផ្ទះចឹងតែម្ដងនឹង។

ក៖ ចុះបើអ្នកខ្លះគេអត់ចេះធ្វើផ្ទះគេធ្វើម៉េចទៅតា?

ខ៖ អូ!!យើងទិញឈើមកជួលជាងគេទៅ។

ក៖ អូ!!គេធ្វើចឹងហោសតា?

ខ៖ បាទ!!យើងជួលជាងគេទៅអោយគេ500-600-700អោយគេចឹងទៅណាស់
ទៅគេធ្វើអោយយើងចឹងទៅចឹង។

ក៖ អូ!!បាទតាបាទនឹង?

ខ៖ រឺមួយមួយទៀតយើងសហការគ្នាលើកដៃគ្នាទៅវិញទៅមកនឹង។

ក៖ លើកនឹងយើងជួយគេលើកក្រោយនឹងគេជួយយើងវិញចឹងទៅ?

ខ៖ ពេលណាយើងធ្វើផ្ទះឧបម៉ាដូចថៅឯងនឹងខ្ញុំចឹង
ថៅឯងមកជួយខ្ញុំពេលដែរខ្ញុំកំពុងរវល់ចឹងហាស។

ក៖ បាទតាបាទនឹង?

ខ៖ ដល់ពេលដែរថៅឯងរវល់វិញខ្ញុំក៏ទៅជួយវិញដែរ។

ក៖ អូ៎!!បាទតាបាទ?

ខ៖ ខ្ញុំជួយវិញតាំងពីដឹក តាំងពីជញ្ជូនតាំងពីកាប់ជើងសសរ
តាំងពីកាប់ចាំងយើងជួយគ្នារហូតនឹង ទាល់តែធ្វើហើយនឹង។

ក៖ អូ៎!បាទៗៗល្អតា ចុះសំរាប់តាគិតថាតាធ្លាប់បានរៀនទេកាលពីមុនហាស
ធ្លាប់បានចូលរៀនដែរទេ?

ខ៖ ខ្ញុំបានរៀននៅវត្តនឹង។

ក៖ ចុះតារៀនបានថ្នាក់ទីប៉ុន្មានដែរតា?

ខ៖ ទេខ្ញុំអត់រៀននៅសាលានឹងគេទេ
ពេលខ្ញុំរៀនចេះល្មមៗៗនឹងខ្ញុំក៏បួសតែម្តងនឹងហាស។

ក៖ អូ៎!!ចឹងហោសតា ចុះកាលពីជំនាន់ណុងតាមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេ?

ខ៖ អត់ទេអត់ចេះទេ។

ក៖ ភាសាបារាំងតាអត់ចេះដែរហោសតា?

ខ៖ អត់ទេនឹង។

ក៖ អូ៎!!បាទតា ចុះសំរាប់តាធ្លាប់មានមិត្តភក្តិដែរស្និទ្ធស្នាលធំធាត់មកជាមួយគ្នាដែរទេតា?

ខ៖ មិត្តភក្តិហោស?

ក៖ បាទតា មិត្តភក្តិរបស់តាមានទេ?

ខ៖ អត់ទេខ្ញុំមិនដែរមានមិត្តភក្តិស្និទ្ធិស្នាលអីទេ ខ្ញុំមានតែម្នាក់ឯងនឹងហាស
ខ្ញុំមិនដែរមានពួកម៉ាក់អីទេ។

កៈ ប៉ុន្តែតាធ្លាបើទៅធ្វើការនៅវាលស្រែដែរហើតា?

ខៈ ទើបតែឥឡូវនឹងទេដែរខ្ញុំធ្វើអត់កើត កាលពីឆ្នាំទៅ
ឆ្នាំទៅមួយនឹងខ្ញុំធ្វើតែនៅបឹងស្រែនឹងហាស។

កៈ អូ៎!!ប៉ុន្តែតាធ្វើអីគេដែរតា?

ខៈ កាប់តែព្រៃ នឹងលើកភ្លឺស្រែលើកអីនឹងហាស។

កៈ មានច្រូតកាត់អីចឹងទៅណតា?

ខៈ មានច្រូតកាត់បោកបែនយើងធម្មតានឹង។

កៈ អូ៎!!បាទតា
ចុះសំរាប់តាគិតថាតាធ្លាប់ធ្វើការងារអីគេខ្លះដែរតាំងពីក្មេងរហូតមកដល់ពេលនេះដែរហាសតា?

ខៈ កាលពីក្មេងនឹងខ្ញុំមិនដែរធ្វើអីទេ
កាលពីក្មេងនឹងខ្ញុំជួយធ្វើតែស្រែម៉ែនឹងដល់ពេលដែរខ្ញុំមានប្រពន្ធ នឹងមានគ្រួសារចឹងទៅ
ខ្ញុំក៏នៅបែកពីគ្រួសារមកនៅជាមួយប្រពន្ធចឹងខ្ញុំក៏ឡើងត្នោតម្តង។

កៈ បាទតាបាទនឹង?

ខៈ ហើយនៅពេលដែរជំនាន់លុនណុលគេធ្វើជាទាហ៊ានទៅខ្ញុំក៏បានគេចពីទាហ៊ាននឹង។

កៈ បាទតាបាទនឹង?

ខៈ ពេលបានគេចពីទាហ៊ានចឹងទៅបានទៅនៅបាត់ដំបង
ពេលដែរទៅបាត់ដំបងចឹងទៅពេលដែរគេ
ឈប់ធ្វើជាទាហ៊ានហើយបានខ្ញុំវិលមកស្រុកវិញនឹង ។

កៈ បាទតា ចុះតាធ្លាប់មានបើកមុខរបរអាជីវកម្មលក់ដូរអីគេដែរទេតា?

ខៈ អត់ទេអត់ដែរទេនឹង។

កៈ ចុះតាមានដែរចិញ្ចឹមសត្វអីទេ ដូចជាចិញ្ចឹមទា មាន់ជ្រូកអីទេ?

ខៈ ទាចិញ្ចឹម គោចិញ្ចឹម។

កៈ តាចិញ្ចឹមលក្ខណៈជាច្រើនរឺមួយក៏តិចដែរតា?

ខៈ មានមេមួយនឹង ឈ្មោលមួយនឹម។

កៈ អូ៎!!ចិញ្ចឹមលក្ខណៈ?

ខៈ មេមួយសំរាប់កូន។

កៈ ចិញ្ចឹមលក្ខណៈជាគ្រួសារណាតា?

ខៈ បាទសំរាប់ឈ្មោលសំរាប់ផ្ទឹម។

កៈ អូ៎!!បាទតា
ចុះលក្ខណៈថាតាជីវិតរបស់តាមានការផ្លាស់ប្តូរអីគេដែរតាំងពីក្មេងរហូតមកដល់ពេលនេះដែរហាសតា?

ខៈ អើរអត់មានការផ្លាស់ប្តូរអីគេដែរទេនឹង មានផ្លាស់ប្តូរទៅណាដឹងតែធ្វើតែស្រែនឹង។

កៈ បាទតាបាទ ចុះគិតថាតាចូលចិត្តពិសារម្ហូបអីគេដែរតា
សំរាប់ចំណង់ចំណូលចិត្តរបស់តាហាស?

ខៈ អើរហូបធម្មតានឹងក្តាម ខ្យង កង្កែប ត្រីអីចឹងទៅណាស់។

កៈ ប៉ុន្តែលក្ខណៈដូចជាសំលម្ជូរអីចឹងហាសតា?

ខៈ សម្លម្ជូរ ប្រហើរ កកូរ ម្ជូរគ្រឿងអីនឹងធម្មតានឹង។

កៈ អូ៎!!ឆា ចៀនអីនឹងហោសតា?

ខៈ បាទ!!ធម្មតាទេនឹង។

កៈ អូ៎!!បាទតា ចុះតាកាលពីក្មេងនឹង តាមានចូលចិត្តលេងល្បែងប្រជាប្រិយ៍អីទេតា?

ខៈ លេងល្បែងប្រជាប្រិយ៍នឹងលេង លេងតែរាំវង្ស លេងតែបោះអង្គុញ។

កៈ ទាញព្រាត លាក់កន្សែងអីនឹងហោសតា?

ខៈ បាទនឹងប្រពៃណីខ្មែរយើងនឹងហាស បើថាល្បែងស៊ីសង
ល្បែងផឹកទឹកត្នោតជូរអីនឹងខ្ញុំអត់ដែរទេ។

កៈ អ៎ូ!!បាទតាបាទ?

ខៈ តាំងពីមួយជីវិតរបស់ខ្ញុំមកនឹងហើយ។

កៈ ចុះតាគិតថាតាចេះច្រៀងដែរទេតា?

ខៈ អើរ.....ធម្មតាទេនឹង។

កៈ មនុស្សតែងតែចេះច្រៀងហើយណាតា?

ខៈ បាទនឹងហើយ។

កៈ ប៉ុន្តែគ្រាន់តែថាមួយចូលចិត្ត នឹងមួយទៀតមិនសូវចូលចិត្តទេ?

ខៈ បាទ!!វាចឹងហើយនឹង។

កៈ ចុះចូលចិត្តច្រៀងដែរតើហីតា?

ខៈ អត់ទេខ្ញុំអត់ដែរដើរលេងច្រៀងទេពីផ្ទះនឹងទេ។

កៈ ចុះតាគិតថាតា?

ខៈ ខ្ញុំគិតថាខ្ញុំលំបាកកំព្រាពីតូចមកខ្ញុំឃើញរង្វង់គ្រួសាររបស់ខ្ញុំលំបាកនឹង ខ្ញុំមិនសូវចេះដើរលេងដើរសើចអីនឹងគេទេខ្ញុំដឹងតែពីរកនឹង។

កៈ បាទតាបាទនឹង?

ខៈ គិតទៅម្ដាយមេម៉ាយ។

កៈ បាទតាត្រូវហើយតា ចុះតាគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់តានឹងចេះលេងឧបករណ៍ភ្លេងដែរទេ?

ខៈ មានបងថ្លៃ។

កៈ គាត់ចេះលេងភ្លេងអីគេដែរតា?

ខៈ គាត់ចេះលេងភ្លេងខ្មែរយើងនឹង ភ្លេងការនឹងហាស។

កៈ អូ៎!!ចុះតាគិតថាផ្ទះរបស់តានឹងមានលក្ខណៈបែបណាដែរតា តាំងពីក្មេងរហូតមកដល់ពេលនេះហាសតា?

ខៈ ផ្ទះរបស់ខ្ញុំនឹងកាលពីនេះផ្ទះធំដែរតើប៉ុន្តែឆេះកាលពីជំនាន់អាពតនឹង។

កៈ អូ៎!!ឆេះហោសតា?

ខៈ គេទំលាក់យន្តហោះមកឆេះទៅ ទំលាក់នៅភូមិនឹងទំលាក់ពីរបីគ្រាប់នឹង។

កៈ ដល់ពេលដែរឆេះចឹងទៅបានយើងធ្វើផ្ទះតូចចឹងទៅ?

ខៈ អត់ទៅបានយើងធ្វើខ្ទមចឹងនៅនឹង។

កៈ អូ៎!!ចឹងហោសតា?

ខៈ កាលពីជំនានអាពតនឹងខ្ញុំផ្ទះធំដែរតើនឹងផ្ទះក្បឿងនឹង។

កៈ បាទតា ចុះផ្ទះរបស់តាកាលពីមុននឹងនរណាគេជាអ្នកធ្វើដែរតា?

ខៈ
ខ្ញុំនឹងតែម្តងនឹងជាអ្នកធ្វើនឹងដូចខ្ញុំនិយាយប្រាប់ចៅឯងចឹងថានរណាចេះធ្វើអីធ្វើណុងទៅៗ ៗណាស់។

កៈ ប៉ុន្តែតាចេះធ្វើផ្ទះ?

ខៈ បាទនឹងហើយ។

កៈ
ចុះតាគិតថាផ្ទះរបស់តាដែរធ្វើនឹងគេមានប្រើឧបករណ៍អីគេខ្លះដែរតាសំរាប់សាងសងនឹង?

ខៈ មានប្រើកាំបិត ពូថៅ រណា ដែកឈូក។

កៈ អូ៎!!មានប្រើឈើ ប្រើដែកគោលអីនឹងហោសតា?

ខៈ បាទនឹងហើយគេប្រើចឹង។

កៈ ចុះតាគិតថាជំនាញអីគេដែរតាចេះស្ទាត់ជំនាញហាសតា?

ខៈ អើរមិនពិតប្រាកដទេចៅ មានចេះនេះតិចនោះតិចគ្រប់មុខនឹង។

កៈ  អូ៎!!បាទតា
ចុះតាគិតថាឪពុកម្តាយរបស់តានឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅតាដែរទេ?

ខៈ  ឪពុកម្តាយរបស់ខ្ញុំនឹងអត់ទេនឹងអត់
អត់ជំនាញទេគាត់ដឹងតែឡើងត្នោតនឹងចាស់ពីដើមដឹងស្រាប់ ហើយគ្រាន់តែចិនពាក់មួក
ចាស់ៗៗពីដើមនឹងអោយតែឃើញចិនពាក់មួកនឹងគេនាំគ្នារត់ចេញអស់ហើយ នឹងហាស។

កៈ  អូ៎!!បាទតាបាទ?

ខៈ  ជំនាន់គាត់ចុះចិនពីដើមនឹងពាក់មួកសរ។

កៈ  បាទតាបាទ ចុះចឹងតាចេះកូរស្ករត្នោត ហើយតាចេះវេញវល្លិ៍ ចេះធ្វើផ្តៅអីអត់ទេតា?

ខៈ  ផ្តៅហោសខ្ញុំអត់មានចេះទេ ខ្ញុំចេះតែវេញខ្សែគោខ្សែអីនឹងហាស។

កៈ  អូ៎!!តាចេះវេញខ្សែគោណាតា?

ខៈ  បាទនឹងហើយចេះ។

កៈ  អូ៎!!បាទតា ចុះតាអាចប្រាប់ខ្ញុំបានទេថាតាជួបការលំបាកបានទេថាតាជួបនៅពេលណា
តាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខៈ  លំបាកតាំងពីខ្ញុំដឹងក្តីនឹង តាំងពីខ្ញុំអត់ឪពុកនឹងមក។

កៈ  លំបាករហូតនឹងហោសតា?

ខៈ  ចឹងខ្ញុំជាមេគ្រួសារផ្ទះ។

កៈ  អូ៎!!ប៉ុន្តែតាពេលណុង?

ខៈ  បងៗៗគេមានគ្រួសារគេបែកនៅជាមួយប្រពន្ធអស់ ខ្ញុំជាមេគ្រួសារផ្ទះនឹង។

កៈ  បាទ!!ពេលណុងគេអោយតាធ្វើអីគេដែរទៅតា?

ខៈ  ខ្ញុំជាមេគ្រួសារផ្ទះខ្ញុំសំរាប់តែធ្វើស្រែ ធ្វើស្ករត្នោតមានតែប៉ុណ្ណឹង។

កៈ
ចុះតាអាចប្រាប់ខ្ញុំបានទេថាតាកាលពីជំនាន់ណុងតាបានទាន់ជំនាន់អ៊ីសារ៉ាក់ដែរណាតា?

ខ៖ ខ្ញុំទាន់តាំងពីជំនាន់អាគីនីនហោស។

ក៖ ជំនាន់អាគីនីនហោសតា?

ខ៖ បាទ សាក់បីអ៊ុំ សាក់មួយអ៊ុត ឆាយណា។

ក៖ បាទតា
ចុះកាលពីជំនាន់ណុងយើងមានការលំបាកអីគេដែរនៅក្នុងស្រុកភូមិយើងដែរតា?

ខ៖ វាមធ្យមនឹង។

ក៖ ដូចជាគេមានសង្គ្រាមហីតា?

ខ៖ អត់មានសង្គ្រាមទេ។

ក៖ ចុះកាលពីជំនាន់អ៊ីសារ៉ាក់វិញតា?

ខ៖ ជំនាន់អ៊ីសារ៉ាក់នឹងសង្គ្រាមជាមួយបារាំងនឹង។

ក៖ ប៉ុន្តែមានប៉ះពាល់ដល់យើងអត់ទេតា?

ខ៖ អត់មានប៉ះពាល់អីទេ។

ក៖ អូ៎!!ចឹងហោសតា?

ខ៖ បារាំងចូលស្រុកភូមិនឹងមក
អ្នកស្រុកអត់មានទៅណាទេដូចថាចៅឯងធ្វើជីវពលអីក៏ដោយនឹង
មកអង្គុយតែលាងជាងត្នោត លាងអំពុង នឹងដុតតែភ្លើងត្នោតចឹងទៅ
គេដឹងតែយើងជាប្រជាជនហើយនឹង។

ក៖ អូ៎!!ចឹងវាអត់មានធ្វើអីយើងទេណាតា?

ខ៖ អត់មានធ្វើអីយើងទេនឹង។

ក៖ ចុះរហូតមកដល់ជំនាន់លុនណុលនឹងមានការលំបាកហើយណាតា?

ខ៖ បាទនឹងមានការលំបាកធ្វើជាកងទ័ព។

ក៖ អូ៎!!តាទៅធ្វើកងទ័ពដែរហោសតា?

ខ៖ អត់ទេ ខ្ញុំអត់មានទេ។

ក៖ បាទតា ចុះពេលណុងលឺថាដូចជាមានធ្លាក់គ្រាប់ធ្លក់អីដែរហោសតា?

ខ៖ អូ៎!!គ្រាប់ផ្លោងមកនឹងធ្លាក់នៅនេះឃើញច្បាស់នឹង។

ក៖ អូ៎!!បាទតាបាទ?

ខ៖ នាំគ្នាចេះតែគេចចូលរណ្ដៅអីចឹងទៅ។

ក៖ បាទ
ចុះសំរាប់តាគិតថានៅពេលដែរជំនាន់ពលពតហាសពេលណុងគេអោយតាធ្វើអីគេដែរទៅ?

ខ៖ ជំនាន់ពលពតនឹងខ្ញុំធ្វើពលករវែកដី។

ក៖ អូ៎!!ចឹងជា?

ខ៖ វែកដីលើកប្រឡាយ។

ក៖ ប៉ុន្តែពេលណុងតាអាយុប៉ុន្មានដែរតា?

ខ៖ ខ្ញុំអាយុច្រើនណាស់អាយុហុកជាងហើយនឹង។

ក៖ អូ៎!!ចឹងតាអាយុហុកជាងហើយតា?

ខ៖ ចុះបើឥឡូវនឹងអាយុ80ឆ្នាំហើយនឹង។

ក៖ ប៉ុន្តែពេលណុងគេអោយតានៅណាដែរទៅតា?

ខ៖ នៅវត្តវិហារខាងលិចនឹង។

ក៖ អូ៎!!ប៉ុន្តែតាចាស់ហើយនឹងគេនៅតែអោយតាធ្វើទៀតនឹងហោសតា?

ខ៖ បាទធ្វើការកើតដូចកាលពីខ្ញុំនៅជំនាន់អាពតនឹង
គេអោយខ្ញុំទៅលើកប្រឡាយចាស់ណាលើក
ប្រឡាយមិនកើតគេអោយលើកទឹកស្រោចស្លែ ស្រោចដំណាំ។

ក៖ អូ៎!!ចឹងយើងត្រូវតែធ្វើការងារអោយគេរហូតហោសតា?

ខ៖ នឹងហើយយើងត្រូវតែធ្វើការអោយគេ បើយើងខ្ជិលគេយកទៅសំលាប់ចោល។

ក៖ ប៉ុន្តែពេលណុងតាមានកូនច្រើនហើយណតា?

ខ៖ កាលនៅណុងកូនរបស់ខ្ញុំមានតែពីរនាក់តើ!!

ក៖ អូ៎!!ចឹងហោសតា?

ខ៖ តើផ្ទះនៅជាមួយ នឹងមីងបងនៅខាងនោះ។

ក៖ បាទចុះពេលណុងច្រើងទៅជាមួយមិត្តភក្តិ រឺមួយយើងទៅជាគ្រួសារដែរតា?

ខ៖ យើងបែកគ្រួសារហើយនឹង។

ក៖ អូ៎!!គ្រួសារគេអោយទៅណាដែរទៅតា?

ខ៖ គ្រួសារនឹងនៅខាងមូលដ្ឋានខ្ញុំចល័តជាប់នឹង ទៅជំនាន់អាពតនឹងគេអោយឯងចេះខាងគ្រូម៉ចឹងទៅ គេអោយទៅខាងពេទ្យចឹងទៅ ពេលដែរដោះពីកន្លែងពេទ្យចឹងទៅគេអោយទៅកន្លែងណាគេអោយទៅ ភូមិកចឹងទៅ ចល័តគ្រប់កន្លែងទាំងអស់នឹង។

ក៖ អូ៎!!គេអោយចល័តប៉ុន្តែនៅក្នុងភូមិនឹងទេ?

ខ៖ នៅក្នុងភូមិនឹង។

ក៖ អូ៎!!ប៉ុន្តែឪពុកម្តាយរបស់តានឹង?

ខ៖ ឪពុកម្តាយរបស់ខ្ញុំគាត់បានស្លាប់អស់ហើយនឹង។

ក៖ មុនពលពតទៀតណតា?

ខ៖ បាទ ម្តាយស្លាប់ជំនាន់អាពត។

ក៖ អូ៎!!ចុះបើបងប្អូននឹងគេអោយទៅណាដែរតាពេលណុង?

ខ៖ អូ៎!!ជំលាសទៅបាត់ដំបង ខ្លះនៅណាៗៗខ្លះទេឆ្ងាយណាស់។

កៈ បាទតា
ចុះសំរាប់នៅពេលដែរជំនាន់ប៉ែតជាងនឹងជាជំនាន់មួយដែរគេអោយចាប់យកធ្វើជាកងទ័ព មែនទេតា?

ខៈ បាទគេចាប់យើងស្ម័គ្រចិត្តគេចាប់។

កៈ អូ៎!!ប៉ុន្តែពេលណុងតាបានធ្វើកងទ័ពនឹងគេដែរទេ?

ខៈ អត់ទេៗៗអត់នឹង។

ក ចឹងអត់ទេណាតា អូ៎!!រហូតទាល់តែដល់ជំនាន់សុខសន្តិភាពណាតា?

ខៈ បាទនឹងហើយ

កៈ ចុះតាគិតថាតាឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរតា?

ខៈ អូ៎!!លំបាកណាស់ក្មួយអើយគេធ្វើបាបគេធ្វើទុកណាស់ជំនាន់អាពតនឹង។

កៈ អូ៎!!បាទតាចឹងយើងចេះតែជំនះវាហើយណាតា ចេះតែខំប្រឹងប្រែងតស៊ូទៅណាតា?

ខៈ ហ៎ោ!!នៅជំនាន់អាពតនឹងគេប្រុងយកខ្ញុំទៅវៃចោលពីរបីដងហើយនឹង។

កៈ ម៉េចបានចឹងហោសតា?

ខៈ តែវាទៅវាមិនរួចជាមួយនឹងខ្ញុំ។

កៈ ដោយសារតែតាអត់មានខុសអីគេទេមែនតា?

ខៈ ខ្ញុំបានតមាត់គេ។

កៈ អូ៎!!តាតមាត់ជាមួយនឹងគេហោសតា?

ខៈ បាទ!!ខ្ញុំតមាត់នឹងចឹងជំនាន់អាពតនឹងខ្ញុំមានសិទ្ធិវៃដែរនឹងតើ!!

កៈ អូ៎!!ម៉េចចឹងហោសតា?

ខៈ ហ៎ោ!!តែប្រើខ្ញុំមិនស្រួលនឹងខ្ញុំវៃដែរឥឡូវនឹងហាស។

កៈ អូ៎!!ចឹងហោសតា?

ខ៖ ហ៎!!យកតានេះទៅវៃចោលឥឡូវនឹងហាស
ខ្ញុំប្រាប់ថាវៃចោលទៅបើវៃខ្ញុំចោលមួយស្រុកឯករាជ្យ វៃខ្ញុំទៅនឹង
បើអ្នកឯងបានធ្វើធំជានាយករដ្ឋមន្រ្តីយកខ្ញុំទៅវៃចោលទៅនឹង។

ក៖ អ្ញុ!!ចឹងហោសតា?

ខ៖ ខ្ញុំអត់មានស្តាយទេអាយុជីវិតរបស់ខ្ញុំមួយនឹង។

ក៖ អ្ញុ!!បាទតាបាទ?

ខ៖ ប៉ុន្តែអ្នកឯងប្រើខ្ញុំហួសច្បាប់ហួសវិន័យខ្ញុំតដៃហើយនឹង។

ក៖ អ្ញុ!!ចឹងហោសតា?

ខ៖ បាទនឹងម៉ោងណាក៏ម៉ោងប្រើៗៗអត់អោយមានពេលម៉ោងសំរាកទេអី។

ក៖ ចុះគេថាម៉េចទៅតា?

ខ៖ សំរាប់គោមនុស្សប្រើគោម៉េចនៅតែមានគេអោយស្មៅគោស៊ី
ចុះទំរាំមនុស្សអ្នកឯងម៉េចមិនអោយ បាយហូប។

ក៖ បាទតាត្រូវហើយនឹងតា?

ខ៖ គេថាហោតានេះស្អប់ដល់ហើយ ខ្ញុំថាខ្ញុំអត់ខ្លាចទេ យកខ្ញុំទៅវៃចោលចឹងទៅ
បើអ្នកឯងវៃខ្ញុំចោលទៅ បានខ្ញុំស្លាប់ចឹងទៅ
បើអ្នកឯងបានខ្ញុំទៅធ្វើជានាយករដ្ឋមន្រ្តីខ្ញុំជួយអរ ប៉ុន្តែអ្នកឯងមិនបានធ្វើ។

ក៖ បាទតាចឹងនឹងជា ចុះខ្ញុំអាចសុំសួរតាបន្តិចទៀតទៅណាស់តា
ចុះតាគិតថាពេលណាដែរតាគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់តាដែ
រហោសតា?

ខ៖ ខ្ញុំអត់រកកន្លែងសប្បាយអត់ឃើញតែម្តងនឹងហាស។

ក៖ អ្ញុ!!ចុះនៅពេលដែរដល់ឥឡូវនឹងសប្បាយហើយណតា?

ខ៖ ឥឡូវនឹងអត់ដឹងថាសប្បាយទេដោយសារតែខ្លួនកាន់តែចាស់
ហើយភ្នែកមើលលែងឃើញ។

ក៖ អ៊ូ!!ចុះតាគិតថាពេលដែរតាការ
រឺមួយក៏ជួបជុំកូនចៅនឹងតាគិតថាសប្បាយហើយណាតា?

ខ៖ បាទសប្បាយមិនលំបាកគ្រាន់បានស្រួលនឹងគេនឹងឯង

ក៖ អ៊ូ!!បាទតាល្អដែរតា ចុះសំរាប់តាគិតថា
កាលពីក្មេងតាធ្លាប់មានគោលបំណង់ថាតាចង់ធ្វើអីគេដែរទេ
ពេលដែរតាបានធំឡើងចឹងហាសតា?

ខ៖ ទេធំឡើងនឹងគោលបំណាងស្រុកពីដើមនឹងអត់មានគោលបំណងថាចង់ធ្វើអីគេដែរទេ
ដឹងតែពីធំឡើងនឹងដឹងតែពីឡើងត្នោត ភ្ជួរស្រែចឹងតែម្តងនឹងហាស

ក៖ អ៊ូ!!បាទតា?

ខ៖ មិនមែនដូចជំនាន់ឥឡូវនឹងទេ។

ក៖ បាទតាបាទ ចុះបើសិនជាចង់អោយតាផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗហាស
តើតាចង់ផ្តែផ្តាំអីទៅពួកគាត់ដែរដែរពួកគាត់អាចធ្វើតាមតាដែរចឹងហាស?

ខ៖ ខ្ញុំគ្រាន់តែផ្តែផ្តាំប៉ុណ្ណឹង ផ្តាំថាកូនអើយអោយស្គាល់ចាស់ ស្គាល់ទុំណាស់កូន។

ក៖ បាទតាបាទ?

ខ៖ អោយស្គាល់ទាប ស្គាល់ខ្ពស់ យើងខំប្រឹងចឹងទៅទាន់ខ្លួននៅក្មេង ខំរកស៊ីចឹងទៅ។

ក៖ បាទតា អោយគាត់ខំប្រឹងរៀនសូត្រអីចឹងទៅហោសតា?

ខ៖ អោយខំប្រឹងរៀនសូត្រអីចឹងទៅបណ្តុះបណ្តាលចៅទៅ។

ក៖ ដើម្បីអោយគាត់មានការងារល្អណាតា?

ខ៖ ថាអញ់វាហួសហើយនឹង។

ក៖ បាទតាបាទត្រូវ ចុះបើសិនជាចង់អោយគាត់ជៀសវៀងវិញនឹង
តើតាចង់អោយគាត់ជៀសវៀងពីការ អីគេខ្លះដែរទៅតា?

ខ៖ ជៀសវៀងពីការលេងល្បែងស៊ីសង នឹងគ្រឿងញៀន គ្រឿងផឹក
ជៀសវៀងបីបួនផ្លូវនឹងអោយបាន។

កៈ ពេលផឹកចឹងកុំអោយបើបរអីចឹងហោសតា?

ខៈ បាទនឹង។

កៈ ខ្លាចមានគ្រោះថ្នាក់ណាតា?

ខៈ យើងជៀសវៀងអីពីស្គាល់ច្បាប់ចរាចរណ៍ផងនឹង។

កៈ បាទដោយសារតែ?

ខៈ កុំអាងតែអញ់ស្រវឹងហើយនឹង អញ់ចេះតែទៅហើយបាតណាបាតណីចឹង ជីវិតរបស់យើងនឹងមិនមែនដាក់លក់នៅផ្សារទេ។

កៈ ត្រូវហើយតា?

ខៈ តែស្លាប់នឹងស្លាប់ហើយ។

កៈ ពេលខ្លះយើងមានបញ្ហា ប៉ុន្តែអាគេនោះគេខំប្រឹងសុវត្ថិភាពហោស គេខំប្រឹងការពារទៅដល់ នឹងយើងស្រវឹង?

ខៈ បាទនឹងហើយចឹង។

កៈ បាទតា
ចឹងសំរាប់តាមានអីចង់ផ្ដែផ្ដាំអីទៅកូនចៅជំនាន់ក្រោយៗរបស់តាផ្សេងអីទៀតទេ?

ខៈ អត់មានអីផ្ដែផ្ដាំទេចៅអើយ មានតែផ្ដែផ្ដាំប៉ុណ្ណឹងអោយខ្ញុំរកខំធ្វើចឹងទៅ។

កៈ បាទតាបាទនឹងហើយ?

ខៈ ខំប្រឹងធ្វើទៅទាន់ខ្លួននៅក្មេង ឥឡូវនឹងនេះលុយវាសំបូរណាស់កូនចៅឯងត្រូវតែខំរកបានវាមានពាក្យចាស់ថាចង់បានឆ្ងាយអោយរករំលក់ ចង់បានសាច់ឆ្ងាញ់នឹងអោយនឿយ

កៈ បាទតាត្រូវហើយនឹងតា?

ខៈ អើរតាយើងឆ្ងាញ់នឹងទាល់តែរកអន្លក។

កៈ បាទតាបាទនឹងតា?

ខៈ បើយើងស្រណុកទាន់យើងនៅពីក្មេង។

ក៖  បាទតាត្រូវហើយតា ចុះមានអីផ្សេងទៀតទេតា?

ខ៖  អត់ទេអត់មានអីទៀតទេនឹង។

ក៖  បាទតាជាចុងក្រោយនឹងខ្ញុំអរគុណច្រើនតាដែរបានផ្តល់ការសំភាសន៍មួយនឹងមកខ្ញុំ ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលា ដើម្បីតំកល់ទុកអោយតាចឹងហាសតា?

ខ៖  បាទៗនឹងមិនអីទេ។

ក៖  បាទចឹងអរគុណច្រើនតាសំរាប់ការសំភាសន៍មួយនឹង៕៕៕